ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា

ប្រចាំអូស្ត្រាលី

**លិខិតជូនពរ**

**បងប្អូនប្រជាពលរដ្ឋខ្មែរជាទីគោរព និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត!**

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ខាងមុខនេះ ខ្ញុំនិងភរិយា សូមជូនពរនិងប្រសិទ្ធិពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ ជូនបងប្អូនប្រជាពលរដ្ឋខ្មែរ សិស្ស និស្សិតកំពុងរស់នៅប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ សូមជួបតែសេចក្តីសុខ សុភមង្គល សុខភាពល្អបរិបូណ៌ កម្លាំងមាំមួន ប្រាជ្ញាវាងវៃ អាយុយឺនយូរ ជៀសផុតពីជម្ងឺកាចសាហាវ និងទទួលបានជោគជ័យគ្រប់ភារកិច្ចថែមទៀត នៅក្នុងឆ្នាំថ្មីខាងមុខ។

ឆ្លៀតក្នុងឱកាសនេះដែរ ដោយជម្ងឺកូវីដ-១៩ កំពុងបន្តគំរាមកំហែងបំផ្លិចបំផ្លាញជីវិតមនុស្សគ្រប់ពេលនិងគ្រប់ទីកន្លែង សូមបងប្អូនទាំងអស់មេត្តាបន្តការប្រុងប្រយ័ត្ន ថែរក្សាសុខភាពឲ្យបានល្អ និងប្រកាន់ខ្ជាប់នូវអនាម័យ និងប្រតិបត្តិខ្ជាប់តាមការណែនាំនៃវិធានការនានារបស់ម្ចាស់ផ្ទះក្នុងការថែទាំសុខភាពនិងរក្សាសុវត្ថិភាពរបស់បងប្អូន។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងដល់គុណព្រះរតនត្រៃយ៍គុណកែវទាំងបី និងវត្ថុស័ក្តិសិទ្ធក្នុងលោក សូមតាមជួយបីបាច់ថែរក្សាការពារថ្នាក់ដឹកនាំ និងបងប្អូនប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស សូមបានប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាត ជាពិសេសសូមបរាសជៀសឆ្ងាយពីជម្ងឺកាចសាហាវជារៀងរហូត។

សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ទទួលនូវសព្ទសាធិការពរដ៏ថ្លៃថ្លា និងទទួលនូវគារវកិច្ច ក្តីនឹករលឹកនិងការគោរពស្រឡាញ់ដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

ថ្ងៃចន្ទ ១ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កង់បេរ៉ា ថ្ងៃទី 12 ខែ មេសា ឆ្នាំ ២០២១

**ឯកអគ្គរាជទូត**

**ចាន់ រតនា**

5 Canterbury Crescent Deakin ACT 2600, Tel: (02) 6273 5867 / 6273 8064, Fax: (02) 6273 1053
E-mail: Cambodianembassy@ozemail.com.au Website: www.embassyofcambodia.org.au